# ផែនការសកម្មភាព
# បណ្តាញសហគមន៍អភិរក្សធនធានធម្មជាតិ
# ថ្នាក់មូលដ្ឋាន
# ( ២០២៥ - ២០២៨ )

រៀបចំឡើងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥

ខេត្តកោះកុង

**មាតិកា**


១. សេចក្តីផ្តើម ........................................ 2

២. គោលបំណង ........................................ 2

៣. តួនាទី និងភារកិច្ចបណ្តាញ ........................................ 3

៤. ផែនការសកម្មភាពសំខាន់ៗរបស់បណ្តាញ ........................................ 4

៥. ផែនការកៀរគរធនធាន និងថវិកា ........................................ 6

៦. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ........................................ 10

## ១. សេចក្តីផ្តើម

**បណ្តាញសហគមន៍អភិរក្សធនធានធម្មជាតិថ្នាក់មូលដ្ឋាន នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង** បាន បង្កើតឡើង នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០២៥ ដែលមានសហគមន៍តំបន់ការពារធម្មជាតិ ចូលរួមសរុប ចំនួន ៦សហគមន៍ រួមមាន សហគមន៍តំបន់តំបន់ការពារធម្មជាតិ ជ្រោយស្វាយ, ព្រាំងចំការក្រោម, ជីខលើ, តាបែន ចំបក់, នាពិសី, កណ្តោល ។ បណ្តាញសហគមន៍នេះ ស្ថិតក្នុងស្រុកស្រែអំបិល និងស្រុកបូទុមសាគរ និងមានផ្ទៃដី សរុប **៤៤៨១.៦៧ ហិកតា** និងមានសមាជិកសរុប **២០៥៧ គ្រួសារ**។

**បណ្តាញសហគមន៍អភិរក្សធនធានធម្មជាតិថ្នាក់មូលដ្ឋាន នៃឧទ្យានជាតិបទុមសាគរ** បានបង្កើតឡើង នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ ដែលមានសហគមន៍តំបន់ការពារធម្មជាតិ ចូលរួមសរុបចំនួន២ រួមមាន សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក និងសហគមន៍តំបន់ការពារធម្មជាតិសម្រស់ទឹកធ្លាក់ឆាយ១២ជាន់។ បណ្តាញសហគមន៍នេះ ស្ថិតក្នុងស្រុកបូទុមសាគរ និងមានផ្ទៃដីសរុប **៥៤៧៣ ហិកតា** និងមានសមាជិកសរុប ១២៧៤ គ្រួសារ។

**បណ្តាញសហគមន៍ទាំង២នេះ បង្កើតឡើងតាមរយៈការបោះឆ្នោតដោយសេរី យុត្តិធម៌ និងត្រឹមត្រូវ** ក្រោមការសម្របសម្រួលដោយ មន្ទីរបរិស្ថានខេត្តកោះកុង រដ្ឋបាលស្រុកស្រែអំបិល រដ្ឋបាលស្រុកបូទុមសាគរ និងមានការគាំទ្រពីអង្គការ PfDA, MPC , MORODOK, NGOF, ActionAid. EU

ការរៀបចំបណ្តាញសហគមន៍នេះគឺស្ថិតក្នុងដំណាក់កាល ដើម្បីរៀបចំផែនការរួមមួយ និងយកចិត្តទុក ដាក់លើបញ្ហាអាទិភាពសំខាន់ៗ ដើម្បីប្រសិទ្ធភាពការពារធនធានធម្មជាតិអោយបានកាន់តែប្រសើរ ក៏ដូចជា លើក កម្ពស់ការកសាងសមត្ថភាព ពង្រឹងការគ្រប់គ្រង ពង្រឹងកិច្ចសហការ និងការសម្របសម្រួល ការចងក្រងព័ត៌មាន ព្រមទាំងមធ្យោបាយ និងសំភារៈចាំបាច់ផ្សេងៗ។ ផែនការបណ្តាញសហគមន៍តំបន់ការពារត្រូវបានរៀបចំឡើង សម្រាប់រយៈពេលបីឆ្នាំចាប់ពីខែកក្កដា ឆ្នាំ២០០៥ ដល់ខែមិថុនា ឆ្នាំ២០២៨ ដោយមានការចូលរួមពីគណៈកម្មការ គ្រប់គ្រង និងសមាជិកបណ្តាញសហគមន៍ សហការជាមួយអង្គការដៃគូ អាជ្ញាធរស្រុក មន្ទីរបរិស្ថាន និងមន្ត្រីតំបន់ ការពារ ព្រមទាំងមានការចូលរួមពីតំណាងសហគមន៍ជលផល រដ្ឋបាលជលផលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ២. គោលបំណង

- ចូលរួមថែរក្សាការពារគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការពារជីវភាពដល់ប្រជានេសាទខ្នាតតូចអោយមានភាពប្រសើរឡើង
- ផ្តល់ការអប់រំ ផ្សព្វផ្សាយដល់ប្រជាសហគមន៍ ជាពិសេសយេឌ័រ ច្បាប់ បទដ្ឋាននានា ទាក់ទង នឹងក្រមបរិស្ថាន និងធនធានធម្មជាតិ

- ជាតំណាង ក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមនានា ក្នុងសហគមន៍ នៅកំរិតថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ

## ៣. តួនាទី និងភារកិច្ចបណ្តាញ

បណ្តាញសហគមន៍តំបន់ការពារធម្មជាតិ ដឹកនាំផ្ទាល់ដោយគណៈកម្មការប្រតិបត្តិ ដែលត្រូវជ្រើសរើសក្នុងចេញពី និងដោយតំណាងសមាជិកសហគមន៍ តាមការបោះឆ្នោតជាសម្ងាត់ គណៈកម្មាធិការនេះត្រូវមានអណត្តិ ៥ឆ្នាំ។ សមាសភាពគណៈកម្មការប្រតិបត្តិមាន ប្រធាន អនុប្រធាន ហិរញ្ញឹក ព្រមទាំងសមាជិកគណៈកម្មការ។

### ក . ប្រធានបណ្តាញ

- ទទួលខុសត្រូវរួម
- ទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធ
- ដោះស្រាយបញ្ហាផ្សេងៗដែលកើតមានពេលអនុវត្តការងារ
- មានសិទ្ធិសម្រេចរាល់ការងារដែលមានក្នុងផែនការ
- មានសិទ្ធិចាត់អញ្ជើញសមាជិកអោយមានការចូលរួមប្រជុំសាមញ្ញ និងវិសាមញ្ញ
- មានសិទ្ធិសម្រេចលើការប្រើប្រាស់ថវិកា
- មានការត្រួតពិនិត្យការងារ
- ផ្សព្វផ្សាយពត៌មានដែលទទួលបានដល់សមាជិក

### ខ. អនុប្រធាន

- បំពេញតួនាទី និងភារៈកិច្ចពេលប្រធានអវត្តមានតាមការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ
- ជំនួយការផ្ទាល់របស់ប្រធានលើសំណើ លើគោលការណ៍ផ្សេងៗអោយពិនិត្យ និងសម្រេច
- ជួយការងារប្រធានក្នុងការធ្វើកំណត់ហេតុរបាយការណ៍
- គ្រប់គ្រងឯកសារ និងជួយលើការទំនាក់ទំនងក្នុង និងក្រៅសហគមន៍

### ឃ. ហិរញ្ញឹក

- គ្រប់គ្រងសាច់ប្រាក់ចំណូល និងចំណាយ
- គ្រប់គ្រងបញ្ជីស្នាមចំណូល និងចំណាយ
- ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ

### ច. សមាជិកគណៈកម្មការ

- សំរបសំរួលសកម្មភាពតាមសហគមន៍នីមួយៗ
- ចែករំលែកពត៌មានសហគមន៍ ដល់បណ្តាញសហគមន៍
- ចែករំលែកពត៌មានបណ្តាញសហគមន៍ ដល់សហគមន៍
- ត្រួតពិនិត្យតាមដានសកម្មភាពក្នុងសហគមន៍
- ធ្វើរបាយការណ៍សកម្មភាពតាមសហគមន៍នីមួយៗ
- ប្រមូលពត៌មាន ទិន្នន័យសហគមន៍ ក្នុងកិច្ចការពារធម្មជាតិ និងអភិវឌ្ឍន៍

## ៤. ផែនការសកម្មភាពសំខាន់ៗរបស់បណ្តាញ

| ល.រ | សកម្មភាព | ទីកន្លែង | ពេលវេលា | ថវិកា | ប្រភពថវិកា | តម្រូវការគាំទ្រ |
|---|---|---|---|---|---|---|
| ១ | **បង្កើនសមត្ថភាពគណៈកម្មការបណ្តាញ** | | | $ 5,200 | | |
| ១.១ | វគ្គបណ្តុះបណ្តាលស្តីពី ក្រមបរិស្ថាន និងធនធានធម្មជាតិ និងវិធីសាស្រ្តល្បាត | ជ្រោយស្វាយ | ១វគ្គ(១វគ្គ/១ថ្ងៃ | $ 500 | | មន្ទីរបរិស្ថាន |
| ១.២ | វគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំ , សម្របសម្រួល | ជីខក្រោម | ១វគ្គ(១វគ្គ/១ថ្ងៃ | $ 500 | | |
| ១.៣ | វគ្គបណ្តុះបណ្តាលស្តី សរសេររបាយការណ៍, កំណត់ហេតុ, សំណើ | អណ្តូងទឹក | ១វគ្គ(១វគ្គ/១ថ្ងៃ | $ 500 | | មន្ទីរបរិស្ថាន |
| ១.៤ | ទស្សនកិច្ចសិក្សា និងចែករំលែកបទពិសោធន៍ | សហគមន៍សង្ឃរុក្ខវ័ន្ត ខេត្តឧត្តមានជ័យ ឬ... (បណ្តាញថ្នាក់មូលដ្ឋាន) | ៣វគ្គ(១វគ្គ/២ថ្ងៃ) | $ 3,000 | | អគ្គនាយកដ្ឋានសហគមន៍ ក្រសួងបរិស្ថាន |
| ២ | **ការស្រាវជ្រាវ និងផ្សព្វផ្សាយ** | | | $ 6,100 | | |
| ២.១ | ប្រមូល និងចង់ក្រងទិន្នន័យ ពត៌មាន(បច្ចុប្បន្នភាពសមាជិកសហគមន៍, ធនធានធម្មជាតិ, ) | ៨សហគមន៍ | ១ដង ( រយៈពេល ៤ខែ ) | $ 800 | | បរិស្ថានស្រុក |
| ២.២ | ប្រជុំបណ្តាញស្តីពី ពិនិត្យនិងកែសម្រួលទិន្នន័យពត៌មានសហគមន៍ | ជ្រោយស្វាយ | ២វគ្គ(១វគ្គ/ ២ថ្ងៃ) | $ 1,500 | | បរិស្ថានស្រុក |
| ២.៣ | ទិវាបរិស្ថានពិភពលោក | ស្រុកស្រែអំបិល | ១វគ្គ/១ថ្ងៃ | $ 600 | | បរិស្ថានស្រុក |
| ២.៤ | យុទ្ធនាការ កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក | ៨សហគមន៍ | ៨វគ្គ(១វគ្គ/១ថ្ងៃ) | $ 800 | | បរិស្ថានស្រុក |
| ២.៥ | ផ្សព្វផ្សាយ៖ កិច្ចការងារអភិរក្ស និងស្វែងរកការគាំទ្រ, លក្ខន្តិកៈបណ្តាញ | ស្រុកស្រែអំបិល | ២៤វគ្គ(១វគ្គ/១ថ្ងៃ) | $ 2,400 | | បរិស្ថានស្រុក |

| | | | | | | |
|---|---|---|---|---|---|---|
| **៣** | **ការងារគ្រប់គ្រងបណ្តាញ និងកិច្ចសហការ** | | | $ 9,020 | | |
| ៣.១ | ប្រជុំប្រចាំត្រីមាស / ឆ្នាំ | ស្រុកស្រែអំបិល , បូទុមសាគរ | ១២វគ្គ(១វគ្គ/១ថ្ងៃ) | $ 3,600 | | បរិស្ថានស្រុក |
| ៣.២ | បង្កើតលក្ខន្តិកៈបណ្តាញ និង គោនយោបាយចំណាយថវិកា | គ្រប់សហគមន៍ | ១វគ្គ/២ថ្ងៃ | $ 1,600 | | អគ្គនាយកដ្ឋានសហគមន៍ ក្រសួងបរិស្ថាន |
| ៣.៣ | ចូលរួមប្រជុំគណៈបញ្ជាការឯកភាពស្រុក | ស្រុកស្រែអំបិល និងស្រុកបូទុមសាគរ | ៣៦ខែ | $ 720 | | |
| ៣.៤ | ចូលរួមភ្ជាប់បណ្តាញនានា ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ក្នុងខេត្ត និងក្រៅខេត្ត | ៣វគ្គ(១វគ្គ/២ថ្ងៃ) | $ 500 | | |
| ៣.៥ | សហការជាមួយមន្ត្រីជំនាញ អាជ្ញាធរ  ល្បាត ទប់ស្កាត់បទល្មើសធនធានធម្មជាតិ | គ្រប់សហគមន៍ | ១២លើក | $ 2,400 | | បរិស្ថានស្រុក |
| ៣.៦ | ចូលរួមលើកកម្ពស់អភិរក្ស និងការពារធនធានធម្មជាតិ និងការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ | សហគមន៍ | ៦លើក | $ 6,00 | | |
| **៤** | **ធនធានសម្ភារៈ** | | | **$ 13,040** | | |
| ៤.១ | ម៉ូតូ ចំនួន ២គ្រឿង, កុំព្យូទ័រ ចំនួន ២គ្រឿង, ម៉ាស៊ីនព្រីនធ័រ ចំនួន ២គ្រឿង | | | $ 8,000 | | |
| ៤.២ | ទិញទូស័ព្ទ ស្មាតហ្វូន សម្រាប់បណ្តាញ ១២គ្រឿង | | | $ 3,600 | | |
| ៤.៣ | អាវភ្លៀង ១២ ឈុត និងស្បែកជើង ២៤គូរ | | | $ 720 | | |
| ៤.៤ | ឯកសណ្ឋាន ២៤ឈុត | | | $ 720 | | |
| **សរុបថវិកា** | | | | **$ 33,360** | | |

## ៤.១ ផែនការសកម្មភាពបណ្តាញសហគមន៍តំបន់ការពារប្រចាំឆ្នាំ ២០២៥_២០២៦

| ល.រ | បរិយាយ | ទីន្លែងអនុវត្ត | ថវិកា | 2025 | | | | | | 2026 | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១ | បង្កើនសមត្ថភាពគណៈកម្មការបណ្តាញ | | $ 2,700 | | | | | | | | | | | | | | | | | | |
| ១.១ | វគ្គបណ្តុះបណ្តាលស្តីពី ក្រមបរិស្ថាន និងធនធានធម្មជាតិ និងវិធីសាស្ត្រល្បាត | ជ្រោយស្វាយ | $ 500 | | | | | | | x | | | | | | | | | | | |
| ១.២ | វគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំ, សម្របសម្រួល | ដីខក្រោម | $ 500 | | | | | | | | | x | | | | | | | | | |
| ១.៣ | វគ្គបណ្តុះបណ្តាលស្តី សរសេរបាយការណ៍, កំណត់ហេតុ, សំណើ | អណ្តូងទឹក | $ 500 | | | | | | | | | | | | x | | | | | | |
| ១.៤ | ទស្សនិច្ចសិក្សា និងចែករំលែកបទពិសោធន៍ | សហគមន៍សង្សរក្តវ័ន្ត ខេត្តឧត្តមានជ័យ ឬ... (បណ្តាញថ្នាក់មូលដ្ឋាន) | $ 1,200 | | | | | x | | | | | | | | | | | | | X |
| ២ | ការស្រាវជ្រាវ និងផ្សព្វផ្សាយ | | $ 4,200 | | | | | | | | | | | | | | | | | | |
| ២.១ | ប្រមូល និងចង់ក្រងទិន្នន័យ_ព័ត៌មាន (បច្ចុប្បន្នភាពសមាជិកសហគមន៍, ធនធានធម្មជាតិ, ) | ៨សហគមន៍ | $ 800 | | | x | x | x | x | | | | | | | | | | | | |
| ២.២ | ប្រជុំបណ្តាញស្តីពី ពិនិត្យនិងកែសម្រួលទិន្នន័យព័ត៌មានសហគមន៍ | ជ្រោយស្វាយ | $ 1,500 | | | | | | | x | | | | | | | | | | | |
| ២.៣ | យុទ្ធនាការៈ ទិវាបរិស្ថានពិភពលោក | ស្រុកស្រែអំបិល | $ 300 | | | | | | | | | | | | x | | | | | | |
| ២.៤ | យុទ្ធនាការ កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក | ៨សហគមន៍ | $ 400 | | | | | | | | x | x | x | x | | | | | | | |
| ២.៥ | ផ្សព្វផ្សាយៈ កិច្ចការងារអភិរក្ស និងស្វែងរកការគាំទ្រ, លក្ខន្តិកៈបណ្តាញ | ស្រុកស្រែអំបិល | $ 1,200 | | | | | | | | | x | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **៣** | **ការងារគ្រប់គ្រងបណ្តាញ** | | $ 4,510 | | | | | | | | | | | | | | | | | | |
| ៣.១ | ប្រជុំប្រចាំត្រីមាស/ឆ្នាំ | ស្រុកស្រែអំបិល, បូទុមសាគរ | $ 1,600 | | | x | | | x | | | x | | | x | | | x | | | x |
| ៣.២ | បង្កើតលក្ខន្តិកៈបណ្តាញ និង គោលនយោបាយចំណាយថវិកា | គ្រប់សហគមន៍ | $ 800 | | | | x | | | | | | | | | | | | | | |
| ៣.៣ | ចូលរួមប្រជុំគណៈបញ្ជាការឯកភាពស្រុក | ស្រុកស្រែអំបិល និងស្រុកបូទុមសាគរ | $ 360 | x | | | x | | | x | | | x | | | x | | | x | | |
| ៣.៤ | ចូលរួមភ្ជាប់បណ្តាញនានា ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ក្នុងខេត្ត និងក្រៅខេត្ត | $ 250 | | | | | | | | | | | | x | x | | | | | |
| ៣.៥ | សហការជាមួយមន្ត្រីជំនាញ អាជ្ញាធរ ល្បាត ទប់ស្កាត់បទល្មើសធនធានធម្មជាតិ | គ្រប់សហគមន៍ | $ 1,200 | | | x | | | x | | | x | | | x | | | x | | | x |
| ៣.៦ | ចូលរួមលើកកម្ពស់អភិរក្ស និងការពារធនធានធម្មជាតិ និងការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ | ៣សហគមន៍ | $ 300 | | | | x | | | | | | x | | | | | | x | | |
| **៤** | **ធនធានសម្ភារៈ** | | **$ 6,720** | | | | | | | | | | | | | | | | | | |
| ៤.១ | ម៉ូតូ ចំនួន ១គ្រឿង កុំព្យូទ័រ ចំនួន ១គ្រឿង ម៉ាស៊ីនព្រីនធ័រ ចំនួន ១គ្រឿង | | $ 4,000 | | x | | | | | | | | | | | | | | | | |
| ៤.២ | ទិញទូរស័ព្ទ ស្មាតហ្វូន សម្រាប់បណ្តាញ ៦ គ្រឿង | | $ 1,800 | | x | | | | | | | | | | | | | | | | |
| ៤.៣ | អាវភ្លៀង ៦ ឈុត និងស្បែកជើង ១២គូ | | $ 460 | | | | x | | | | | | | | | | | | | | |
| ៤.៤ | ឯកសណ្ឋាន ១២ឈុត | | $ 460 | | | | | x | | | | | | | | | | | | | |

## ៤.២ ផែនការសកម្មភាពបណ្តាញសហគមន៍តំបន់ការពារប្រចាំឆ្នាំ ២០២៧_២០២៨

| ល.រ | បរិយាយ | ទីន្លែងអនុវត្ត | ថវិកា | 2027 | | | | | | | | | | | | 2028 | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 |
| ១ | **បង្កើនសមត្ថភាពគណៈកម្មការបណ្តាញ** | | $ 2,500 | | | | | | | | | | | | | | | | | | |
| ១.១ | វគ្គបណ្តុះបណ្តាលស្តីពី ក្រមបរិស្ថាន និងធនធានធម្មជាតិ និងវិធីសាស្ត្រល្បាត | ជ្រោយស្វាយ | $ 500 | | x | | | | | | | | | | | | | | | | |
| ១.២ | វគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំ, សម្របសម្រួល | ជីខក្រោម | $ 500 | | | | | | | x | | | | | | | | | | | |
| ១.៣ | វគ្គបណ្តុះបណ្តាលស្តី សរសេរបាយការណ៍, កំណត់ហេតុ, សំណើ | អណ្តូងទឹក | $ 500 | | | | | | | | | | | | | x | | | | | |
| ១.៤ | ទស្សនកិច្ចសិក្សា និងចែករំលែកបទពិសោធន៍ | សហគមន៍សង្ឃរុក្ខវ័ន្ត ខេត្តឧត្តមានជ័យ ឬ... (បណ្តាញថ្នាក់មូលដ្ឋាន) | $ 1,000 | | | | | | | | | | | x | | | | | | | |
| ២ | **ការស្រាវជ្រាវ និងផ្សព្វផ្សាយ** | | $ 1,900 | | | | | | | | | | | | | | | | | | |
| ២.១ | ប្រមូល និងចង់ក្រងទិន្នន័យពត៌មាន (បច្ចុប្បន្នភាពសមាជិកសហគមន៍, ធនធានធម្មជាតិ, ) | ៨សហគមន៍ | $ 000 | | | | | | | | | | | | | | | | | | |
| ២.២ | ប្រជុំបណ្តាញស្តីពី ពិនិត្យនិងកែសម្រួលទិន្នន័យពត៌មានសហគមន៍ | ជ្រោយស្វាយ | $ 0,00 | | | | | | | | | | | | | | | | | | |
| ២.៣ | យុទ្ធនាការៈ ទិវាបរិស្ថានពិភពលោក | ស្រុកស្រែអំបិល | $ 300 | | | | | | X | | | | | | | | | | | | X |
| ២.៤ | យុទ្ធនាការ កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក | ៤សហគមន៍ | $ 400 | | x | | | | | x | | | | | | x | | | x | | |
| ២.៥ | ផ្សព្វផ្សាយៈ កិច្ចការងារអភិរក្ស និងស្វែងរកការគាំទ្រ, លក្ខន្តិកៈបណ្តាញ | ស្រុកស្រែអំបិល | $ 1,200 | | | x | | | | | | | | | | | | x | | | |
| ៣ | ការងារគ្រប់គ្រងបណ្តាញ | | $ 4,510 | | | | | | | | | | | | | | | | | | |
| ៣.១ | ប្រជុំប្រចាំត្រីមាស/ឆ្នាំ | ស្រុកស្រែអំបិល , បូទុមសាគរ | $ 1,600 | | | x | | | x | | | x | | | x | | | x | | | x |

| | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.២ | បង្កើតលក្ខន្តិកៈបណ្តាញ និង គោនយោបាយចំណាយថវិកា | គ្រប់សហគមន៍ | $ 800 | | x | | | | | | | | | | | | | | | | |
| ៣.៣ | ចូលរួមប្រជុំគណៈបញ្ជាការឯកភាពស្រុក | ស្រុកស្រែអំបិល និងស្រុកបូទុមសាគរ | $ 360 | x | | | x | | | x | | | x | | | x | | | x | | |
| ៣.៤ | ចូលរួមភ្ជាប់បណ្តាញនានា ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ក្នុងខេត្ត និងក្រៅខេត្ត | $ 250 | | | | | | x | x | | | | | | | | | | x | x |
| ៣.៥ | សហការជាមួយមន្ត្រីជំនាញ អាជ្ញាធរ ល្បាត ទប់ស្កាត់បទល្មើសធនធានធម្មជាតិ | គ្រប់សហគមន៍ | $ 1,200 | | | x | | | x | | | x | | | x | | | x | | | x |
| ៣.៦ | ចូលរួមលើកកម្ពស់អភិរក្ស និងការពារធនធានធម្មជាតិ និងការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ | ៣សហគមន៍ | $ 300 | | | | x | | | | | | x | | | | | | x | | |
| **៤** | **ធនធានសម្ភារៈ** | | **$ 6,720** | | | | | | | | | | | | | | | | | | |
| ៤.១ | គាំទ្រម៉ូតូ ចំនួន ១គ្រឿង កុំព្យូទ័រ ចំនួន ១គ្រឿង, ម៉ាស៊ីនព្រីនធ័រ ចំនួន ១គ្រឿង | | $ 4,000 | x | | | | | | | | | | | | | | | | | |
| ៤.២ | ទិញទូរស័ព្ទ ស្មាតហ្វូន សម្រាប់បណ្តាញ ៦គ្រឿង | | $ 1,800 | x | | | | | | | | | | | | | | | | | |
| ៤.៣ | អាវភ្លៀង ៦ ឈុត និងស្បែកជើង ១២គូ | | $ 460 | | x | | | | | | | | | | | | | | | | |
| ៤.៤ | ឯកសណ្ឋាន ១២ឈុត | | $ 460 | | x | | | | | | | | | | | | | | | | |

## ៥. ផែនការកៀរគរធនធាន និងថវិកា

ចូលរួមលើកកម្ពស់កិច្ចសហការ ផ្សព្វផ្សាយ និងកៀរគរធនធានលើគម្រោងសកម្មភាព ផែនការ និងគំនិតផ្តួចផ្តើមគម្រោងសំណើផ្សេងៗ សម្រាប់បណ្តាញ និងសហគមន៍ជាសមាជិកបណ្តាញ ប្រមូលធនធានផ្សេងៗ សម្រាប់ការអនុវត្តផែនការ និងជាប្រយោជន៍សម្រាប់សហគមន៍តំបន់ការពារ។ ប្រភពធនធាន ដែលជាសក្តានុពលរួមមាន៖

- ភាគទានរបស់សហគមន៍តំបន់ការពារជាសមាជិកបណ្តាញ
- អំណោយពីសប្បុរសជន
- ថវិកាពីរាជរដ្ឋាភិបាល (មូលនិធិអភិវឌ្ឍន៍នៅតាមមូលដ្ឋានជាដើម)
- អង្គការជាតិ និងអង្គការអន្តរជាតិ និងដៃគូសហការ និងភ្នាក់ងារអភិវឌ្ឍន៍

## ៦. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ នឹងត្រូវបានរៀបចំជារបាយការណ៍ ដើម្បីណែនាំការប្រតិបត្តិ របស់បណ្តាញ ហើយត្រូវបានធ្វើឡើងជាប្រចាំ តាមរយៈកិច្ចប្រជុំត្រីមាស និងជាពិសេសកិច្ចប្រជុំប្រចាំឆ្នាំ ក្នុងការឆ្លុះបញ្ចាំងពីសមិទ្ធិផល បញ្ហាប្រឈម មេរៀនជាបទពិសោធន៍ ការងារបន្ត និងសំណូមពរផ្សេងៗ សម្រាប់ការងារបណ្តាញ។ ការឆ្លុះបញ្ចាំងប្រចាំឆ្នាំ ដែលត្រូវបានសម្របសម្រួលដោយបណ្តាញ ដោយមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរ និងភាគីពាក់ព័ន្ធ។ លទ្ធផលពីការចែករំលែក និងឆ្លុះបញ្ចាំង ត្រូវចងជាឯកសារ ឬរបាយការណ៍សម្រាប់ងាយស្រួលប្រើប្រាស់ និងចែករំលែក ដើម្បីធ្វើឲ្យការអនុវត្តកាន់តែប្រសើរឡើង និងដើម្បីអភិវឌ្ឍផែនការអនាគត។